CITY OF LONG BEACH **PRESS RELEASE**

**សេចក្តីប្រកាសព័ត៌មាន**

ថ្ងៃទី 6 ខែកុម្ភៈ ឆ្នាំ 2021

ទំនាក់ទំនង ៖ មជ្ឈមណ្ឌលព័ត៌មានរួម នៃសាលាក្រុងឡុងប៊ិច, jic@longbeach.gov

សម្រាប់ការផ្សព្វផ្សាយភ្លាមៗ

# ក្លីនិកវ៉ាក់សាំងឡុងប៊ិច សម្រាប់ជួយភ្ជិត គម្លាតសមធម៌ ក្នុង ការទទួលបានវ៉ាក់សាំង

ឡុងប៊ិច, CA - សព្វថ្ងៃនេះ នាយកដ្ឋានសុខាភិបាល និងសេវាមនុស្ស នៃសាលាក្រុងឡុងប៊ិច (នាយកដ្ឋានសុខាភិបាល) រៀបចំឱ្យមាន ក្លីនិកវ៉ាក់សាំងដំបូង ជាផ្នែកមួយ នៃកម្មវិធី ផ្សព្វផ្សាយ ដែលផ្តល់វ៉ាក់សាំង ដល់ប្រជាពលរដ្ឋ នៅតាមភូមិស្ថានដែលប្រឈមហានិភ័យខ្ពស់ តាមរយៈក្លីនិកតាមសហគមន៍ ខ្នាតតូច ។ ក្លីនិកដំបូង ដែលបម្រើជូនមនុស្សជំ មានអាយុ 65 ឆ្នាំ និងច្រើនជាងនេះ ដែលនិយាយភាសាអេស្ប៉ាញ ជាចំបងនេះ បានចាប់ដំណើរការ នៅ ឧទ្យានស៊ីលវើរ៉ាដូ តាមគេហទំព័រ ហើយបានចាក់វ៉ាក់សាំង ចំនួន 500 ដូស ។ បុគ្គលិកនិយាយ ភាសាអេស្ប៉ាញ មានវត្តមាននៅទីតាំងនោះ ដើម្បីជួយសមាជិកសហគមន៍ ហើយឆ្លើយសំណួរ នានា ។

ចៅហ្វាយក្រុង រ៉ូប៊ើត ហ្គាសៀ (Robert Garcia) បានគូសបញ្ជាក់ថា «ជាការសំខាន់ ត្រូវចុះទៅឱ្យ ដល់ប្រជាពលរដ្ឋ នៅទូទាំងទីក្រុង ហើយចាក់វ៉ាក់សាំង ជូនប្រជាពលរដ្ឋ នៅសហគមន៍មាន ចំណូលទាប និងប្រឈមហានិភ័យខ្ពស់ ។» «យើងខ្ញុំប្តេជ្ញាបើកដំណើរការក្លីនិកទាំងនេះ សម្រាប់ ប្រជាពលរដ្ឋវ័យចាស់ និងសមាជិកសហគមន៍ផ្សេងៗ ទៀត ដែលរស់នៅក្នុងតំបន់រងផលប៉ះ ពាល់ ។»

ក្លីនិកចល័តទាំងនេះ ផ្តោតលើភូមិស្ថាន ដែលមានប្រវត្តិទទួលសេវាមិនបានគ្រប់គ្រាន់ នៅ ឡុងប៊ិច ដោយមានការណាត់ជួប ត្រូវបានជ្រើសរើស ក្នុងចំណោមអ្នកចុះឈ្មោះនៅ VaxLB ឬ ធ្វើ ឡើង ដោយសហការជាមួយ ដៃគូមិនរកប្រាក់ចំណេញ និងដៃគូសហគមន៍ ដែលបម្រើការជូន សហគមន៍ទាំងនេះ ។ បន្ថែមលើការចាក់វ៉ាក់សាំង ជូនប្រជាពលរដ្ឋវ័យចាស់ តាមរយៈក្លីនិក ចល័ត សាលាក្រុងកំពុងស្វែងរកឱកាសបន្ថែមទៀត នៅពេញមួយខែកុម្ភៈ ដើម្បីបម្រើជូន សហគមន៍ ដែលរងគ្រោះដោយសារ COVID-19 ខ្លាំងជាងគេ រួមទាំងបុគ្គល នៅតាមផ្ទះ និង មជ្ឈមណ្ឌលមើលថែមនុស្សចាស់ រហូតទាល់តែបំពេញបានតាមសេចក្តីត្រូវ ចប់សព្វគ្រប់ ។ ដូច រាល់ដងក្លីនិកទាំងនេះ គឺពឹងអាស្រ័យតាម ភាពអាចរកបាន វ៉ាក់សាំង ។

គិតត្រឹមថ្ងៃទី 6 ខែកុម្ភៈ មានករណី COVID-19 ចំនួន 49,356 នៅឡុងប៊ិច ហើយប្រជាពលរដ្ឋ ចំនួន 714 នាក់ បានបាត់បង់ជីវិត ដោយសារវីរុសនេះ ។ វ៉ាក់សាំងច្រើនជាង 52,000 ដូស ត្រូវ បានចាក់ជូនប្រជាពលរដ្ឋ ។

CITY OF LONG BEACH

# PRESS RELEASE

សម្រាប់ព័ត៌មានចុងក្រោយបំផុត អំពី COVID-19 ដែលមានសេចក្តីលំអិត អំពីសកម្មភាពទាំងអស់ ដែលសាលាក្រុងឡុងប៊ិច កំពុងអនុវត្ត ដើម្បីរក្សាឱ្យប្រជាពលរដ្ឋ មានសុវត្ថិភាពនោះ សូមចូលទៅ longbeach.gov/COVID19 ហើយតាម @LongBeachCity នៅលើ Facebook, Twitter និង Instagram ។

# # #